# ធម៌គិរីមានន្ទ

## ទុត្តិសាការបាឋោ

អំពីអាការៈ ៣២

**អត្ថិ ឥមស្មឹំ កាយេ** មានរូបក្នុងកាយនេះ

| | |
|---|---|
| **កេសា** | សក់ទាំងឡាយ |
| **លោមា** | រោមទាំងឡាយ |
| **នខា** | ក្រចកទាំងឡាយ |
| **ទន្តា** | ធ្មេញទាំងឡាយ |
| **តចោ** | ស្បែក |
| **មំសំ** | សាច់ |
| **នហារូ** | សរសៃទាំងឡាយ |
| **អដ្ឋី** | ឆ្អឹងទាំងឡាយ |
| **អដ្ឋិមិញ្ជំ** | ខួរក្នុងឆ្អឹង |
| **វក្កំ** | ទាច ឬសួត ( តម្រងបស្សាវៈ) |
| **ហទយំ** | បេះដូង |
| **យកនំ** | ថ្លើម |
| **កិលោមកំ** | វ៉ាវ ( ស្បែកស្តើងខាងក្នុង រងបន្ទាប់ស្បែកក្រៅ : វាវគោ, វាវឈ្លូស ) ។ |
| **បិហកំ** | ក្រពះ |
| **បប្ផាសំ** | សួត |

| | |
|---|---|
| **អន្តំ** | ពោះវៀនធំ |
| **អន្តគុណំ** | ពោះវៀនតូច |
| **ឧទរិយំ** | អាហារថ្មី |
| **ករីសំ** | អាហារចាស់ |
| **បិត្តំ** | ប្រមាត់ |
| **សេម្ហំ** | ស្លេស្ម |
| **បុព្វោ** | ខ្ទុះ |
| **លោហិតំ** | ឈាម |
| **សេទោ** | ញើស |
| **មេទោ** | ខ្លាញ់ខាប់ |
| **អស្សុ** | ទឹកភ្នែក |
| **វសា** | ខ្លាញ់រាវ |
| **ខេឡោ** | ទឹកមាត់ |
| **សិង្ឃាណិកា** | ទឹកសម្បោរ |
| **លសិកា** | ទឹករំអិល |
| **មុត្តំ** | ទឹកមូត្រ |
| **មត្ថកេមត្ថលុង្គន្តិ** | ខួរក្នុងក្បាល ។ |

**ទ្វត្តឹសាការបាឋោ និដ្ឋិតោ**

ចប់ អាការៈ ៣២ ។

# ធម៌គិរីមានន្ទ

អំពីរោគទាំងឡាយ ដែលកើតក្នុងរូបរាងកាយនៃមនុស្សលោកគ្រប់ៗរូប

**ពហុទុក្ខោ ខោ អយំ កាយោ ពហុអាទីនវោតិ**

រូបកាយនេះ មានទុក្ខច្រើន មានទោសច្រើនមែនពិត

**ឥតិ ឥមស្មឹ កាយេ វិវិធា អាពាធា ឧប្បជ្ជន្តិ**

អាពាធ គឺជំងឺតម្កាត់ទាំងឡាយផ្សេងៗ តែងកើតឡើង ក្នុងកាយនេះ ដូច្នេះ ។

| | |
|---|---|
| **សេយ្យថីទំ** | អាពាធនោះ ដូចម្តេចខ្លះ? |
| **ចក្ខុរោគោ** | គឺរោគក្នុងភ្នែក |
| **សោតរោគោ** | រោគក្នុងត្រចៀក |
| **ឃានរោគោ** | រោគក្នុងច្រមុះ |
| **ជិវ្ហារោគោ** | រោគក្នុងអណ្តាត |
| **កាយរោគោ** | រោគក្នុងកាយ |
| **សីសរោគោ** | រោគក្នុងក្បាល |
| **កណ្ណរោគោ** | រោគខាងក្រៅត្រចៀក |
| **មុខរោគោ** | រោគក្នុងមាត់ |
| **ទន្តរោគោ** | រោគត្រង់គល់ធ្មេញ |
| **កាសោ** | រោគក្អក |
| **សាសោ** | រោគហឺត |
| **បិនាសោ** | រោគខាងក្រៅច្រមុះ |
| **ឌហោ** | រោគក្តៅក្រហាយ |
| **ជរោ** | រោគស្គាំងស្គម |

| | |
|---|---|
| **កុច្ឆិរោគោ** | រោគក្នុងផ្ទៃ |
| **មុច្ឆា** | រោគខ្យល់ចាប់ វិលមុខ |
| **បក្ខន្ទិកា** | រោគធ្លាក់ឈាម |
| **សុលា** | រោគចុកសៀត |
| **វិសូចិកា** | រោគចុះរាក |
| **កុដ្ឋំ** | រោគឃ្លង់ |
| **គណ្ឌោ** | រោគពក |
| **កិលាសោ** | រោគស្រែង |
| **សោសោ** | រោគរីងរៃ |
| **អបមារោ** | រោគឆ្កួតជ្រូក |
| **ទទ្ទុ** | រោគដំណួចពិស |
| **កណ្ឌុ** | រោគរមាស់ |
| **កច្ឆុ** | រោគកមគ្រិន |
| **រខសា** | រោគកញ្ជ្រឹល ( តាមអដ្ឋកថា ប្រែថា រោគមហារីក) |
| **វិតច្ឆិកា** | រោគកមរលាយ |
| **លោហិតំ** | រោគឈាម |
| **បិត្តំ** | រោគប្រមាត់ |
| **មធុមេហោ** | រោគប្រមេះទឹកបាយ |
| **អំសា** | រោគឫសដូងបាតដុះជុំវិញទ្វារធំ |
| **បិឡកា** | រោគរលកកែវ |

| | |
|---|---|
| **ភគន្ទលា** | រោគឫសដូងបាតដុះខាងក្នុង (១) |
| **បិត្តសមុដ្ឋានា អាពាធា** | អាពាធកើតអំពីប្រមាត់ |
| **សេម្ហសមុដ្ឋានា អាពាធា** | អាពាធកើតអំពីស្លេស្ម |
| **វាតសមុដ្ឋានា អាពាធា** | អាពាធកើតអំពីខ្យល់ |
| **សន្និបាតិកា អាពាធា** | អាពាធកើតអំពីសន្និបាត គឺកំរើកប្រមាត់ ស្លេស្មនិងខ្យល់ប្រជុំគ្នា ។ |
| **ឧតុបរិណាមជា អាពាធា** | អាពាធកើតអំពីរដូវប្រែប្រួល |
| **វិសមបរិហារជា អាពាធា** | អាពាធកើតអំពីការផ្លាស់ប្តូរឥរិយាបថមិនស្មើគ្នា |
| **ឱបក្កមិកា អាពាធា** | អាពាធកើតអំពីសេចក្តីព្យាយាម (របស់អ្នកឯទៀត មានចាប់ចង វាយកាប់ជាដើម) ។ |
| **កម្មវិបាកជា អាពាធា** | អាពាធកើតអំពីវិបាករបស់កម្ម |
| **សីតំ** | អាពាធកើតអំពីត្រជាក់ |
| **ឧណ្ហំ** | អាពាធកើតអំពីក្តៅ |
| **ជិឃច្ឆា** | អាពាធកើតអំពីសេចក្តីឃ្លាន |
| **បិបាសា** | អាពាធកើតអំពីសេចក្តីស្រេក |
| **ឧច្ចារោ** | អាពាធកើតអំពីឧច្ចារៈ |
| **បស្សាវោតិ** | អាពាធកើតអំពីបស្សាវៈ ។ |

(១) អដ្ឋកថា ប្រាប់ថា " ឫសដូងបាតដែលដុះខាងក្នុង គឺត្រង់ចន្លោះទ្វារធំនិងទ្វារតូច"

# សំនួរ ធម៌អភិធម្ម

**សំនួរ:** ចុះពាក្យថា រូបនោះ មានប៉ុន្មានយ៉ាង?

**ចម្លើយ:** រូបនេះមាន ២ យ៉ាងគឺ: មហាភូតរូប១, ឧបាទានរូប១ ។

**សំនួរ:** តើមហាភូតរូបនេះ បើចែកតទៅទៀតមានប៉ុន្មានយ៉ាងគឺអ្វីខ្លះ?

**ចម្លើយ:** មាន ៤ យ៉ាងគឺ: បថវីធាតុ១, អបោធាតុ១, តេជោធាតុ១, វាយោធាតុ១ ។

## បថវីធាតុ

**សំនួរ:** ចុះបថវីធាតុនោះ តើមានប៉ុន្មានយ៉ាង?

**ចម្លើយ:** បថវីធាតុ គឺធាតុដីៗនោះមាន ២០យ៉ាង ដូចមានខាងក្រោមនេះគឺ:

១). **កេសា** "សក់ទាំងឡាយ" មាន៩លានសរសៃ មានពណ៌ខ្មៅ មានឫសចាក់ចុះទៅក្នុងស្បែកក្បាលប្រវែង១ចុងស្រូវ សក់នេះដុះតែក្នុង១រន្ធមួយសរសៃ មិនដែលមានដល់ពីរសរសៃឡើយ, សក់នេះអ្នកប្រាជ្ញទាំងឡាយ លោកកំណត់ពិចារណា ដោយបដិកូលកម្មដ្ឋានថា ជាទីគួរខ្ពើមរអើម មាន៥យ៉ាងគឺ: បដិកូលដោយសម្បុរ១, បដិកូលដោយស្ថាន១, បដិកូលដោយក្លិន១, បដិកូលដោយទីកើត១, បដិកូលដោយទីលំនៅ១ ត្រូវជា៥ប្រការ, សម្រាប់ឱ្យសត្វពិចារណាដូចបុគ្គលបរិភោគជនាហារ កាលបើបានឃើញសក់ធ្លាក់ចុះមកលើភោជនាហារ ក៏ខ្ពើមរអើមចាប់ចោលចេញ ពុំបានបរិភោគនោះឡើយ, សក់នេះជាទីស្រឡាញ់ពេញចិត្តតែកាលតាំងនៅលើក្បាលវេលាដែលជ្រុះចុះ មកកាលណាហើយ ក៏មានសេចក្ដីខ្ពើមរអើមពន់ប្រមាណណាស់, សក់នេះដុះនៅលើក្បាលត្រាំនៅក្នុងខ្ទុះនឹងឈាមទឹកស្លេស្មជាដើម ឧបមាដូចជា បន្លែឬស្មៅដុះនៅជិតផ្ទះឬបង្គន់ជារបស់ស្មោកគ្រោក ដូចជាលាមកអាក្រក់គួរឱ្យខ្ពើមរអើមពេកណាស់ ។

២). **លោមា** "រោមទាំងឡាយ" មានប្រមាណ៩ម៉ឺនរណ្ដៅ សម្បុរសក៏មាន លឿងក៏មាន ខ្មៅក៏មាន ឧបមាដូចឫសត្នោត ។

ឯទីដែលកើតរោមនោះគឺកើតពីសាច់ស្បែកដែលរុំកាយ វៀរលែងតែទីដែលមានសក់ដុះ នឹងផ្ទៃបាតដៃ ឬផ្ទៃបាតជើងចេញ ។ រោមនេះ មានឫសចាក់ចុះទៅប្រវែងមួយពងចៃ ដុះតែក្នុងមួយរន្ធមួយសរសៃៗ មិនដុះមួយរន្ធ២ពីរបីសរសៃនោះឡើយ រោមនេះ ជាបដិកូលកម្មដ្ឋានមាន ៥ ប្រការ ដូចគ្នានឹងសក់ដែរ ។

៣). **នខា** "ក្រចកទាំងឡាយ" មាន២០ ហើយមានពណ៌សដូចស្រកាត្រី ដុះនៅចុងម្រាមទាំង២០គឺម្រាមដៃ១០ នឹងម្រាមជើង១០, ក្រចកនេះ ជាបដិកូលកម្មដ្ឋាន៥ប្រការដូចគ្នា ។

៤). **ទន្តា** "ធ្មេញទាំងឡាយ" មាន៣២ គឺចំពោះអ្នកដែលមានវាសនា បើអ្នកដែលឥតវាសនាវិញ មានធ្មេញត្រឹមតែ ២៤ខ្លះ ឬថា ២៩ខ្លះ ។

ធ្មេញនេះ មានសម្បុរស មានសណ្ឋានទីទៃៗពីគ្នាគឺ: ចុងធ្មេញ៤នោះ បីដូចគ្រាប់ឃ្លោកដុះរៀងគ្នា, ឯចង្កូមទាំង៤មានសណ្ឋានដូចផ្កាម្លិះក្រពុំ មានចុងស្រួចឡើង មានឫសដុះចុះទៅក្រោម, ចង្កូម១បន្ទាប់ចេញមកម្ខាងៗ មាន៤សណ្ឋានដូចកង់រទេះ ឯចុងឫសដែលចាក់ចុះទៅនោះមានចំពាម៣, ខាងលើមានចំពាម២ ។

ធ្មេញនេះ បង្កើតពីឆ្អឹងខាងលើនិងឆ្អឹងក្រោម ជាទីស្មោកគ្រោកជាប់ស្លេស្មខ្លះ ជាប់ឈាមខ្លះ ជាប់ទឹកមាត់លាមកអាក្រក់ខ្លះ បើពុំបានជំរះតែមួយវេលា ក៏មានក្លិនស្អុយ ឆ្អាប ជាទីគួរខ្ពើមរអើមដល់បុគ្គលទាំងពួង ធ្មេញនេះតែកើតមកហើយ ក៏តែងតែបាក់បែករង្គោះចេញទៅវិញជាធម្មតា ឥតមានខ្លឹមសារអ្វីនោះទេ ធ្មេញនេះ ក៏ជាបដិកូលដោយកម្មដ្ឋាន ៥ ប្រការដែរ ។

៥). **តចោ** "ស្បែក" ស្បែកនេះ បើបកយកតែសម្បកក្រៅចេញពីខ្លួន ប្រមូលឱ្យមូលមក មានប្រមាណប៉ុនផ្លែពុទ្រា មានសម្បុរទីទៃៗពីគ្នា ខ្លះស ខ្លះខ្មៅ ខ្លះលឿង ខ្លះក្រហម ។

ស្បែកដែលរុំសាច់នោះ មានឧបមា ដូចជាសម្បកដង្កូវនាង ស្បែកជើង ដូចជាគេពាក់ទ្រនាប់ជើង ស្បែកកំភួនជើង ដូចជាគេយកស្លឹកត្នោតមករុំ ស្បែកលោង ដូចជាថង់ដែលបុគ្គលច្រកអង្ករពេញ ស្បែកត្រគាក ដូចជាដំរងទឹក ស្បែកខ្នងដូចជាស្បែកដែលគេរុំផែនក្ដារ ស្បែកពោះដូចស្បែករុំជើង ស្បែកដើមទ្រូងមានសណ្ឋាន៤ជ្រុង ស្បែកដៃទាំងពីរ ដូចស្បែកដែលគេរុំបំពង់ធ្នូ ស្បែកខ្នងដៃ ដូចស្រោមកាំបិតកោរ ស្បែករុំកាយ ដូចថង់ដាក់កូនសោ ស្បែកក ដូចគេយកបន្ទះឫស្សីមកត្បាញជាបំពង់តៗគ្នា ស្បែកមាត់មានរន្ធព្រោកៗ ដូចជាសម្បុកកណ្ដូប ស្បែកក្បាលដូចជាស្លោកបាត្រ ស្បែកនេះ ក៏ជាបដិកូលដោយកម្មដ្ឋាន ៥ ប្រការដូចគ្នាដែរ ។

៦). **មំសំ** "សាច់" សាច់នេះ មានប្រមាណ ៩០០ដុំ មានសម្បុរប្រហម ដូចជាផ្កាចារ មានសណ្ឋានទីទៃៗពីគ្នា សាច់កំភួនជើងនោះ ដូចជាស្លឹកត្នោតដែលគេវេចឱ្យមូលហើយដំកល់ទុក សាច់ភ្លៅ ដូចជាអង្រែថ្ម, សាច់ចុងត្រគាកនោះ ដូចដុំថ្មចង្ក្រាន, សាច់ស្នងនោះ ដូចផែននៃស្ករ, សាច់ឆ្អឹងជំនីនោះ ដូចជាដីស្អិតដែលគេលាបជញ្ជាំង, សាច់ដោះទាំងពីរ ដូចជាដីដែលគេយកទៅចងព្យួរទុក, សាច់ទាំង ៩០០ដុំនេះ ដូចជាគេរុំជាប់នឹងឆ្អឹងទាំង ៣០០ កំណាត់, សាច់ក្រោមជាប់នឹងឆ្អឹង សាច់លើជាប់ស្មើនឹងស្បែក សាច់ទាំងនេះ គឺពុំដែលមានខ្លឹមសារអ្វីនោះទេ ជាអសុភស្មោកគ្រោក គួរខ្ពើមរអើមក្រៃពេក ។

៧). **នហារូ** "សរសៃទាំងឡាយ" សរសៃនេះ មានប្រមាណ ៩០០សរសៃ មានសម្បុរ-សសុទ្ធ ចងព័ទ្ធរឹតរួតឆ្អឹងទាំង ៣០០កំណាត់ ដូចរូបយន្តដែលគេដោតក្រងខ្សែយន្ត ។

ឯសរសៃធំទាក់ទៅតាមឆ្អឹងជំនីខាងឆ្វេង៥សរសៃ ខាងស្ដាំ៥សរសៃ, សរសៃធំចាក់ចុះទៅ

តាមឆ្អឹងខ្នងខាងឆ្វេង៥សរសៃ នឹងខាងស្តាំង៥សរសៃ, សរសៃធំៗនេះមកជួបប្រជុំគ្នានៅត្រង់ក ទាំងអស់, សរសៃធំស្ទួទៅតាមដៃស្តាំដៃឆ្វេងម្ខាងៗមាន១០គឺសរសៃខ្នងដៃ៥ បាតដៃ៥ត្រូវជា១០, សរសៃធំដែលស្ទួទៅតាមជើងម្ខាងៗមាន១០ៗ នឹងពួរជើងម្ខាងៗ មាន៥ៗសរសៃ រួមទៅត្រូវជា សរសៃ៦០ ដែលរឹតរួតនូវកាយ, ឯសរសៃតូចៗបានថ្លក់ប្រទាក់គ្នានឹងឆ្អឹងតូចៗហើយចងភ្ជាប់នឹង សរសៃធំៗ ដែលមាននៅក្នុងកាយ ៣កំណាត់ ។

៨). **អដ្ឋិ** "ឆ្អឹងទាំងឡាយ" ឆ្អឹងនេះ មានប្រមាណ ៣០០កំណាត់ លើកតែធ្មេញ ៣២ ចេញ គឺឆ្អឹងដៃ៦៤, ឆ្អឹងជើង៦៤, ឆ្អឹងខ្ចីដែលអាស្រ័យនូវសាច់នោះ៦៤, ជើងមួយៗមានឆ្អឹងកែង២ៗ ឆ្អឹងកជើង២, ឆ្អឹងជង្គង់២, ឆ្អឹងភ្លៅ១, ឆ្អឹងចង្កេះ២, ឆ្អឹងចង្កូរខ្នង៨, ឆ្អឹងជំនី២៤, ឆ្អឹងដើមទ្រូង១៤, ឆ្អឹងចុងដង្ហើម១, ឆ្អឹងស្មា២, ឆ្អឹងចង្កូយស្មា២, ឆ្អឹងក៧, ឆ្អឹងថ្គាម២, ឆ្អឹងដើមដៃ២, កដៃមួយៗមានឆ្អឹង២ៗ, ឆ្អឹងភ្នែក២, ឆ្អឹងត្រចៀក២, ឆ្អឹងថ្ពាស១,ឆ្អឹងបង្ហើយ១, ឆ្អឹងច្រមុះ១, ឆ្អឹងក្បាល៩ ត្រូវជាឆ្អឹងមាន៣០០កំណាត់ ។

ឯឆ្អឹងទាំងនេះ មានសម្បុរសសុទ្ធមានសណ្ឋានទ្រង់ទ្រាយទីទៃៗពីគ្នា គឺឆ្អឹងចុងម្រាមជើង ដូចផ្លែកែស, ឆ្អឹងថ្នាំងម្រាមកណ្តាល ដូចគ្រាប់ខ្នុរណាំង, ឆ្អឹងម្រាមជើងខាងគល់ដូចដើមបបុស ឆ្អឹងនោះបីដូចជាគំនរផ្កា, ឆ្អឹងកែងជើងដូចកំពឹងត្នោត, ឆ្អឹងភ្នែកគោ ដូចផ្លែអង្គញ, ឆ្អឹងកជើង ដូចបណ្តូលចេក, ឆ្អឹងស្មងជើងតូចដូចដងធ្នូ, ឆ្អឹងស្មងជើងធំ ដូចឆ្អឹងពស់ស្វិត, ឆ្អឹងក្បាលជង្គង់ ដូចពពុះទឹក ដែលជាប់ទៅនឹងឆ្អឹងភ្លៅ ដូចផ្លែក្រូចទុំ ដែលគេកាត់ចុងចេញ, ឆ្អឹងចង្កេះទាំងពីរជាប់ គ្នាតែមួយ ដូចចង្ក្រានស្មូនឆ្នាំង បើញែកឱ្យផ្សេងគ្នា ដូចដង្កាប់ជាងទង, ឆ្អឹងត្រគាកដែលនៅក្នុង ចង្កេះ ដូចពស់ផ្កាប់មុខបើកពពារ មានប្រហោងតូចៗចំនួន៧ឬ៨, ឆ្អឹងខ្នងទាំងអស់ ខាងក្នុងដូចជា វង់នៃផែនសំណ ដែលគេដឹកលទុកលើៗគ្នា ខាងក្រៅដូចរបៀបកូនផ្គាំ, ឆ្អឹងទ្រនុងខ្នង២ឬ៣ តាមចន្លោះឆ្អឹងខ្នងទាំងនោះ ដូចធ្មេញរណារ, ឆ្អឹងជំនីទាំង ២៤ បើមិនពេញបរិបូណ៌ទេ ដូចកណ្តៀវ

ដែលមិនពេញបរិបូណ៌ បើពេញបរិបូណ៌នោះ ដូចកណ្ដៀវដែលពេញបរិបូណ៌ រូបរួមទាំងអស់ ដូចស្លាបមាន់ស ដែលគេលាតសន្ធឹង, ឆ្អឹងបេះដូងដូចរលាវែក, ឆ្អឹងទ្រូងទាំង១៤ ដូចស្លាបគ្រុឌចាស់, ឆ្អឹងភ្នែកដូចដងកាំបិតស្ដាន់តូច ឆ្អឹងចង្កួយស្មា ដូចផ្លែចបរបស់ជនក្នុងប្រទេស ឈ្មោះសីហៈលៈដែលរិចរិលអស់, ឆ្អឹងដើមដៃដូចក្របកញ្ចក់, ឆ្អឹងដើមដៃខាងចុង ដូចគ្រាប់ត្នោតមួយគូ, ឆ្អឹងភ្នែកដៃដូចផែនសំណ ដែលគេរំលាយជាមួយដិកល់ទុក, ឆ្អឹងខ្នងដៃ ដូចគំនរឫសរុនដែលគេយកមកដំរៀប, ឆ្អឹងម្រាមដៃខាងគល់ដូចខ្លុយ, ឆ្អឹងកណ្ដាល ដូចគ្រាប់ខ្នុរមិនពេញ, ឆ្អឹងខាងចុង ដូចគ្រាប់ល្មៀង, ឆ្អឹងកទាំង៧ ដូចថ្នាំងឫស្សី ដែលគេដោតនឹងឈើតាមលំដាប់គ្នា, ឆ្អឹងចង្កាខាងក្រោម ដូចខ្សែដង្កាប់ដែករបស់ជាងទង ខាងលើដូចផ្លែកាំបិតសកអំពៅ, ឆ្អឹងថ្ងាសដូចស្នូកស័ង្ខដែលគេដាក់ផ្កាប់, ឆ្អឹងរណ្ដៅភ្នែកនឹងរណ្ដៅច្រមុះ ដូចគ្រាប់ត្នោតខ្ចី ដែលគេយកសាច់ក្នុងចេញ, ឆ្អឹងគុម្ពត្រចៀក ដូចស្រោមកាំបិតកោររបស់ខ្មាន់ប្រកេស ឆ្អឹងថ្ងាសនឹងឆ្អឹងគុម្ពត្រចៀក ដែលជាប់គ្នាជាផ្ទាំង៧ ខាងលើដូចក្អមដាក់ខ្លាញ់ពេញ ឆ្អឹងបង្ហើយ ដូចត្រឡោកដូងកោង ដែលគេកាត់មាត់ចេញ ឆ្អឹងក្បាលដូចរលាឃ្លោកសាយដៀវចាស់ដែលគេស្រែះទុក ។

បណ្ដាឆ្អឹងទាំងឡាយនេះ ឆ្អឹងក្បាលនៅលើឆ្អឹងក៧នៅលើឆ្អឹងខ្នង៧នៅលើឆ្អឹងចង្កេះ៧នៅលើឆ្អឹងភ្លៅ៧នៅលើឆ្អឹងជង្គង់៧នៅលើឆ្អឹងស្មង៧នៅលើឆ្អឹងភ្នែកគោ៧នៅលើឆ្អឹងជើង មានសភាពគួរខ្ពើរអើមក្រៃពេក ។

៩). **អដ្ឋិមិញ្ជំ** "ខួរក្នុងឆ្អឹង" មានសម្បុរស តាំងនៅក្នុងឆ្អឹងទាំង៣០០កំណាត់ បើឆ្អឹងធំខួរក៏ច្រើន បើឆ្អឹងតូចខួរក៏តិច ឧបមាដូចផ្ដៅ ដែលបុគ្គលរោលភ្លើងឱ្យឆ្អិនហើយបកសម្បកចេញហើយដាក់ចូលទៅក្នុងបំពង់ឫស្សីនោះ ។

១០). **វក្កំ** "ទាចឬសួត" មានសម្បុរក្រហម ដូចផ្លែឧទុម្ពរស្រគាល ជាប់នៅជាមួយនឹងថ្លើម សួត បេះដូងទាំងអស់នេះ ។

១១). **ហទយំ** "បេះដូង ឬចិត្ត" នៅចំពាក់កណ្ដាលដើមទ្រូង មានសម្បុរក្រហម ដូចផ្កាបទុមជាត ឯខាងក្នុងបេះដូងនោះប្រៀបដូចផ្លែននោងទុំ ហើយមានរន្ធប៉ុនផ្លែក្រូចឆ្មារ មានសណ្ឋានដូចផ្កាឈូកក្រពុំ បើបុគ្គលមានប្រាជ្ញាឈ្លាសវាងវៃ បេះដូងនោះរីកបន្ដិច, បើបុគ្គលនោះល្ងង់ពុំសូវមានតម្រេះប្រាជ្ញាទេ បេះដូងនោះដូចផ្កាឈូកស្រពោន, ខាងក្នុងមានទឹករក្សាចិត្តចំនួន១ទូកដៃ បើបុគ្គលជារាគៈចរិត ទឹករក្សាចិត្តក្រហម, ទោសៈចរិត ទឹករក្សាចិត្តខ្មៅ, មោហៈចរិត ទឹករក្សាចិត្តក្រហមដូចទឹកលាងសាច់, វិតក្កៈចរិត ទឹករក្សាចិត្តពណ៌ដូចកាកផ្លែពាយជ្រុង, សទ្ធាចរិត ទឹករក្សាចិត្ត ពណ៌ដូចផ្កាកណ្ណិកា, បញ្ញាចរិត ទឹករក្សាចិត្តថ្លាមិនល្អក់កករឡើយ ដូចកែវមណី ។

១២). **យកនំ** "ថ្លើម" មានសម្បុរក្រហម ដូចផ្កាឈូកក្រហមដិកល់នៅក្នុងចន្លោះខាងស្ដាំ រាងដូចស្លឹករលួសផ្អុង បើអ្នកមានប្រាជ្ញាចុងថ្លើមឆែក, បើអ្នកអ័ប្បឥតប្រាជ្ញាចុងថ្លើមនោះមិនឆែកឡើយ, បើខ្លួនធំម្ដេចម្ដាតែមានប្រាជ្ញា ថ្លើមនោះតូច បើមនុស្សនោះតូច តែជាអ្នកឆោតល្ងង់ ថ្លើមនោះក៏ធំពុំមានឆែកឡើយ ។

១៣). **កិលោមកំ** "វាវ ឬក្រដាស" មាន២យ៉ាងគឺ វាវ ដែលរុំថ្លើម សួត បេះដូង១, វាវដែលរុំឆ្អឹងទាំង ៣០០កំណាត់១, មានដូចសំពត់ទុកូលពស្ត្រចាស់ ។

១៤). **បិហកំ** "ក្រពះ" មានសម្បុរ ដូចផ្កាកន្ទិស ឬថា ដូចអណ្ដាតកូនគោខ្មៅក៏មាន បើគេប្រហារដោយគ្រឿងសស្ត្រាវុធ ឱ្យតែក្រពះនោះលៀនចេញមកខាងក្រៅទៀងតែពីស្លាប់ ។

១៥). **បប្ផាសំ** "សួត" សួតនេះមានភេទជាសាច់៣៣ដុំជាប់គ្នា មានសម្បុរក្រហមប្រឿងៗដូចផ្លែឧទុម្ពរស្រគាល បើបុគ្គលនោះអត់អាហារពុំបានបរិភោគ ភ្លើងក៏ឆេះឆ្លលដល់សួតៗក៏ក្រៀម,

បើបុគ្គលនោះ បានបរិភោគអាហារឆ្អែតបរិបូណ៌ហើយ ភ្លើងធាតុនោះក៏ឆេះអស់អាហារ ដែលបាន បរិភោគចូលទៅ ស្លួតនោះក៏ស្រស់ឡើងដូចពីដើមវិញ ឯស្លួតនោះស្ថិតនៅត្រង់ចន្លោះដោះទាំងពីរ សំយ៉ុងចុះមកគ្របថ្លើមនឹងសាច់ស្លួត ។

១៦). **អន្តំ** "ពោះវៀនធំ" បើពោះវៀន របស់មនុស្សប្រុសប្រវែង៣២ហត្ថ, បើពោះវៀន មនុស្សស្រីមាន ២៤ហត្ថ, វៀនជាផ្នត់២៤ផ្នត់ ទៅលើទល់ក ចុះទៅក្រោមដល់ទ្វារធំ ពោះវៀននេះ មានសម្បុរស ខាងក្នុងពោះវៀននោះ ដូចសម្បុរខ្នុរណាំង ក្រៅពីនោះរមួល។ ក្នុងពោះវៀននោះ សឹងច្រឡំដោយហ្វូងដង្កូវ៣២ចំពូក ដង្កូវនេះ វារទៅវារមកនៅក្នុងពោះវៀនធំ បើខានបរិភោគ អាហារចូលទៅ ដង្កូវទាំងនោះវាងើបក្បាលឡើងច្រូង ហើយវាជញ្ជក់ថ្លើម បេះដូង ស្លួត ។

ថាបើបុគ្គលបរិភោគអាហារចូលទៅបាន១ម៉ាត់ ឬ២ម៉ាត់ ដង្កូវទាំងនោះក៏នាំគ្នាមកប្រជែង ដណ្តើមស៊ីអាហារដែលចូលទៅនោះ ដង្កូវទាំងនោះតែងកើតតែងស្លាប់នៅក្នុងពោះវៀនធំនោះឯង ។ ពោះវៀនធំនោះ ជាលំនៅជាទីស្លាប់ ជាទីកើតនៃដង្កូវទាំងឡាយ ឧបមាដូចបុគ្គលកាត់ក្បាល ពស់ ហើយបំពេនទុកក្នុងទីណាមួយ ។

១៧). **អន្តគុណំ** "ពោះវៀនតូច" ពោះវៀនតូចនេះ ចងទាក់នឹងពោះវៀនធំ មានសម្បុរ ដូចជានីលុប្បល (ផ្កាឧប្បលខៀវ) បើបុគ្គលធ្វើការជាទម្ងន់ពោះវៀនតូចនោះក៏ធូរ បើពោះវៀន តូចនោះធូរហើយ ពោះវៀនធំក៏ធូរតាម បើនៅស្ងៀមដូចប្រក្រតី ពោះវៀនតូចនោះ រឹតរួត ពោះវៀនធំ គង់នៅដូចពីដើម ។

១៨). **ឧទរិយំ** "អាហារថ្មី" បើបុគ្គលបរិភោគអាហារចូលទៅនោះ គឺល្អិតដោយធ្មេញ ក្រោមនឹងធ្មេញលើ ដូចជាត្បាល់បុក អណ្តាតនោះ ដូចបុគ្គលយកដៃត្រឡប់បង្វិល កាលបើអាហារ

ចូលដល់ចុងអណ្តាតជ្រួតជ្រាបច្រឡំនឹងទឹកមាត់រាវ លុះដល់ដើមអណ្តាតជ្រួតជ្រាបច្រឡំនឹងទឹកមាត់ខាប់ ក្លិនរសពិសារក៏បាត់ទៅ ។ លុះដល់ពោះហើយ មុខគួរឱ្យខ្ពើមរអើមក្រៃពេក ឧបមាដូចកំអួតឆ្កែ ពុំនោះសោត ដូចបាយដែលគេត្រាំសិទ្ធិអម្បោះ កាលបើអាហារនោះ ធ្លាក់ចូលទៅដល់ក្នុងពោះហើយ ក៏ប្រឡាក់ដោយទឹកលាមកអាក្រក់ បើបុគ្គលនោះមានស្លេស្មច្រើនអាហារនោះខៀវ បើមានខ្ទុះច្រើនអាហារនោះច្រឡំទៅដោយទឹកស្អុយ បើមានឈាមច្រើនអាហារនោះក្រហម ភ្លើងធាតុដុតអាហារនោះបក់ឡើងឱ្យហ្វូងដង្កូវដណ្តើមគ្នា អាហារដែលបុគ្គលលេបចូលទៅនោះ ចែកចេញជា៥ចំណែកគឺៈ បានទៅដង្កូវស៊ីមួយចំណែក, ភ្លើងធាតុដុតមួយចំណែក, បានជាទឹកមូត្រមួយចំណែក, បានជាលាមកមួយចំណែក, បានជាសាច់ស្បែកឈាមមួយចំណែក, រួមជា៥ចំណែក ។

១៩). **ករីសំ** "អាហារចាស់" ដែលភ្លើងធាតុដុតឱ្យល្អិត ដូចគេបុកនឹងថ្មល្អិហើយ ក៏ហូរចូលទៅតាមចន្លោះពោះវៀនធំ ចូលទៅខាប់ជាដុំ ហើយក៏តាំងនៅក្រោមពោះវៀនធំ ក្នុងពោះវៀនយើងនេះ ឧបមាដូចថ្នាំងឬស្សី ប្រវែងអង្គុលីដ៏ពេញដោយដី ដូចម្តេចមិញ, ឯអាហារចាស់នោះសោតក៏ដូចដី ដែលបុគ្គលដាក់ក្នុងបំពង់ឬស្សីនោះឯង ។

២០). **មត្ថកេមត្ថលុង្គំ** "ខួរក្នុងក្បាល" មូលបីដូចជានំ ឯអាហារជ្រួតជ្រាបសព្វសពាង្គកាយ ហើយចម្រើនឱ្យសាច់ សម្បុរឈាម អាហារដែលបុគ្គលបរិភោគទៅនោះ ទោះតិចក្តី ច្រើនក្តីក៏បែងចេញជា៥ចំពូក ដូចបានពណ៌នាមកនុ៎ះឯង ឯអាហារដែលភ្លើងធាតុនោះពុះផុលឡើង ឧបមាដូចឆ្នាំងបាយពុះ ធម្មតា បាយពុះកន្ទក់លំអង រមែងអណ្តែតតាមពពុះឡើង មកជាប់នឹងមាត់ឆ្នាំងដូចម្តេចមិញ, អាហារដែលយើងបានបរិភោគចូលទៅ ភ្លើងធាតុ រមែឆេះផុលឡើងមកជាប់នៅត្រចៀក ភ្នែក ច្រមុះ ដូច្នោះដែរ ។

ពពុះអាហារ ដែលភ្លើងធាតុបក់ឡើង មកជាប់នៅក្នុងរន្ធត្រចៀក រន្ធច្រមុះ ភ្នែក សន្ទតិថា

អាចម៍ច្រមុះ ត្រចៀក ភ្នែក, បើមកជាប់នៅធ្មេញ សន្មតិថា សង្អេចធ្មេញ, បើមកជាប់អណ្ដាត សន្មតិថា អុលអណ្ដាត ភ្លើងធាតុដុតឱ្យល្អិតឡើង ក៏បែកចេញជាល្មក់ អាចម៍ បែងចេញឱ្យចម្រើនសាច់នូវសម្បុរទាំងពួង ។

ខួរក្នុងក្បាលនេះ ឧបមាដូចម្សៅ ដែលបុគ្គលលញ់ឱ្យមូលជាដុំ មានសម្បុរសដូចដំឡូងខ្ទឹពាដុំ ប្រជុំគ្នានៅក្នុងឆ្អឹងក្បាល មុខគួរឱ្យខ្ពើមក្រៃពេក ។ លោកអ្នកប្រាជ្ញមានប្រាជ្ញា គម្បីពិចារណាអំពីភ្លើងនេះខួរអសុភ ដូចម្ដេចមិញ, ខួរក្នុងក្បាលនៃយើងទាំងពួង ក៏ដូចគ្នាពុំមានប្លែកនោះដែរ ។

កាយទាំងមូល ជារបស់ពុកផុយរលួយគួរខ្ពើមរអើមណាស់ ដោយអំណាចអវិជ្ជា ចូលមកបិទបាំងប្រាជ្ញាមិនឱ្យឃើញយល់ ហើយក៏ប្រកាន់យកតែសក្កាយទិដ្ឋិជាត្រីមុខ គឺប្រកាន់ថា ខ្លួនអញនេះល្អ មានជាតិខ្ពស់ មានត្រកូលខ្ពស់ ពូជពង្សជាអ្នកថ្កើងថ្កាន ហើយមើលងាយដល់អ្នកដទៃថា ជាមនុស្សជូជាតិសាមាន្យ ត្រកូលថោកទាប រូបរាងក៏ពុំស្មើនឹងអញឡើយ ។

ព្រះសម្មាសម្ពុទ្ធទ្រង់បានសម្ដែងជាច្រើនអន្លើ ដើម្បីហាមមិនឱ្យបៀតបៀនដល់សត្វលោកផងគ្នា និងមិនឱ្យមានការចងនូវពៀរវេរាដល់គ្នា ព្រោះជាហេតុនាំឱ្យខាតនូវជាតិកំណើតខ្លួន ។

## ព្រះអង្គទ្រង់ ឧទានគាថា

**ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ**

**អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ៗ**

"ក្នុងកាលណា ៗ ក៏ដោយ ធម្មតាពៀរទាំងឡាយ ក្នុងលោកនេះ មិនដែលស្ងប់រម្ងាប់ដោយការចងពៀរឡើយ, តាមការពិត ពៀរទាំងឡាយ តែងស្ងប់រម្ងាប់ ដោយការមិនចងពៀរ, នេះជាធម៌ចាស់មានយូរណាស់មកហើយ" ។

## Roeung Nāṅyakkhinī

**Na hi verena verāni,sammantīdha kudācanaṃ;**
**averena ca sammanti, esa dhammo sanantano.**

Hatred never cease through hatred in this world; through love alone they cease.This is an eternal law.

# អបោធាតុ

អបោធាតុ គឺធាតុទឹក មាន១២យ៉ាងគឺ:

១). **បិត្តំ** "ទឹកប្រមាត់" ឯទឹកប្រមាត់នេះមាន២យ៉ាងគឺ ពទ្ធបិត្តៈ១, អពទ្ធបិត្តៈ១ ។ ពទ្ធបិត្តៈនោះ មានសណ្ឋាន ដូចផ្លែននោងនៅក្នុងទីជាចន្លោះ បេះដូង ថ្លើម សួត, ប្រមាត់នោះថា កាលបើកម្រើកហើយ សត្វផងទាំងពួងទៅជាឆ្កួតងងឹងងើពុំដឹងអ្វីនោះឡើយ, ឯពទ្ធបិត្តៈនោះ មានសម្បុរ ដូចផ្កាថ្កុលស្វិត ប្រមាត់នេះ ជ្រាបសព្វសពាង្គកាយ ចៀសតែសក់ រោម ក្រចកចេញ, ក្រៅពីនោះ ជ្រាបចូលសព្វសពាង្គកាយទាំងអស់ ឥតមានសេសសល់ឡើយ, ប្រមាត់នេះ កាលបើមានការកម្រើកហើយ តែងធ្វើភ្នែកឱ្យក្រហម ឱ្យវិលមុខ នឹងធ្វើខ្លួនឱ្យកម្រើកញាប់ញ័រ រួមទៅត្រូវជាប្រមាត់មាន ២ ប្រការ ដូចបានរៀបរាប់មកនេះឯង ។

២). **សេម្ហំ** "ស្លេស្ម" ស្លេស្មនេះ មាននៅក្នុងរាងកាយ នៃមនុស្សទាំងពួង មានប្រមាណមួយបាត្រ សម្បុរដូចទឹកស្លឹកខ្លុងដឹកល់នៅក្នុងពោះ កាលបើបរិភោគអាហារចំណីអ្វី១ចូលទៅក្នុងបំពង់កហើយ អាហារនោះក៏វែកស្លេស្ម ចែកជាចន្លោះហើយក៏លិចចុះទៅក្នុងខាងក្រោមពោះ កាលបើអាហារលិចចុះទៅក្រោម ស្លេស្មនោះក៏ប្រមូលគ្នានៅដូចដើមវិញ មានគណៈនាដូចជាស្រះដ៏ពេញទៅដោយចក ឬសារាយ ទាំងពួង កាលបើបុគ្គលយកដុំដីមួយចោលទៅក្នុងស្រះនោះ ចក ឬសារាយ ក៏ជិតមកវិញ មានប្រការម្ដេចមិញ, ចំណែកអាហារ ដែលបានបរិភោគចូលទៅហើយ ក៏ជិតមកវិញដូចដើម មានឧបមេយ្យដូច្នោះដែរ ។

ស្លេស្មនេះ ប្រមូលបិទបាំងនៅលើក្លិនអសោចក្នុងពោះ មិនឱ្យហុយឡើងមកលើបាន បើពុំមានស្លេស្មបិទបាំងទេ សំអុយអសោចក្នុងពោះនោះក៏ហុយឡើង ស្លេស្មនេះ មានឧបមាដូចផែនក្ដារបិទបង្គន់ មិនឱ្យក្លិនអសោចនោះហុយឡើងមកលើបាន យ៉ាងណា ស្លេស្មក៏បិទបាំងក្លិនអសោចក្នុងកាយមិនឱ្យហុយ ឬចំហាយឡើងមកខាងលើយ៉ាងនោះដែរ ។

៣). **បុព្វោ** "ខ្ទុះ" ខ្ទុះនេះមានពណ៌ក្រហម ស លឿង ទីទៃៗពីគ្នា បើត្រូវមុតនឹងអ្វីៗខ្លាំង ឈាមក៏មកគុំទៅជាខ្ទុះត្រង់កន្លែងដែលមុតនោះឯង ។

៤). **លោហិតំ** "ឈាម" មាន២ប្រការគឺៈ សំសរណលោហិត១, សន្និចិតលោហិត១ ។

សន្និចិតលោហិត មានសម្បុរដូចជាទឹកស្បែងខាប់នៅក្នុងពោះឡើងទៅដល់សួត ថ្លើម បេះដូង បើឈាមនោះពុំបានលិចដល់ថ្លើម សួត បេះដូង ក្នុងកាលណា ក៏បណ្តាលឱ្យទៅជាផ្សារ ឆ្អួលក្តៅក្នុងដើមទ្រូង ក្នុងកាលនោះដែរ ។ ថាបើឈាមនេះតាំងនៅដោយធម្មតា ក៏ត្រជាក់ដើមទ្រូង ត្រជាក់ចិត្ត មានសិរីសួស្តី មានសម្បុរនោះដូចប្រេងល្ងថ្លា, ចំណែកឯ សំសរណលោហិត មានសម្បុរ ដូចទឹកល័ក្តក្រហមថ្លា ។

៥). **សេទោ** "ញើស" ញើសនេះ ជាទីតាំងនៅក្នុងរោមទាំងពួង មានសម្បុរដូចប្រេងល្ងថ្លា ថាបើត្រូវក្តៅកាលណាក៏ហូរចេញពីរន្ធរោមទាំងពួង កាលណោះដែរ ។

៦). **មេទោ** "ខ្លាញ់ខាប់" មានសម្បុរដូចរមៀត មានសណ្ឋានដូចសំពត់ទុកូលព័ស្រ្តចាស់ នៅចន្លោះស្បែកនឹងសាច់ បើបុគ្គលនោះស្គម ខ្លាញ់ក៏តិច បើធាត់ខ្លាញ់ក៏ច្រើន ។

៧). **អស្សុ** "ទឹកភ្នែក" ទឹកភ្នែកនេះ បីដូចជាប្រេងថ្លានៅក្នុងរង្វង់ភ្នែកទាំងពីរ ថាបើមានការកើតទុក្ខទោមនស្ស កាលណាហើយ ទឹកភ្នែកនោះក៏ហូរចេញមក ឬសើចខ្លាំងពេក ឬអត់ងងុយណាស់ទៅ ក៏បណ្តាលឱ្យទឹកភ្នែកហូរចេញមកដែរ ហើយក៏ស្រក់ដោយរង្វង់ភ្នែកនេះឯង ។

៨). **វសា** "ខ្លាញ់រាវ" មានសម្បុរដូចប្រេងដូង ដែលតាំងនៅក្នុងស្បែកពោះ ច្រមុះ,

ថ្វាសនឹងចុងស្មា ថាបើបុគ្គលត្រូវកំដៅភ្លើងក្តី កំដៅព្រះអាទិត្យក្តី ឬធ្វើការសារពើអ្វី១ជាទម្ងន់ខ្លាញ់រាវនោះ ក៏ហូរចេញមកជ្រាបអស់ទាំងខ្លួន ។

៩). **ខេឡោ** "ទឹកមាត់" មានសម្បុរ-ស តាំងនៅក្នុងថ្ពាល់ បើឃើញវត្ថុអ្វី១ដែលគួរខ្ពើមរអើម ទឹកមាត់នោះក៏ហូរចេញមក ឬឃើញគេបរិភោគអ្វី១ដែលមានរសជាតិដ៏ឆ្ងាញ់ ក៏កើតសេចក្តីស្រេកឃ្លានឡើង ទឹកមាត់នោះក៏ហូរចេញមក, ពុំនោះសោតបរិភោគរបស់មានរសជូរ ប្រៃ ហឹរជាដើម ក៏បណ្តាលឱ្យហូរចេញមកដែរ ឬមិនបាច់បរិភោគអ្វី១សោះទេ ស្រាប់តែហូរចេញមកឯង១ក៏មាន, បើទឹកមាត់គ្មានទេ បំពង់កក៏ខះស្ងួតពុំបានសេចក្តីសុខស្រួលឡើយ ។

ទឹកមាត់រាវនៅចុងអណ្តាត ទឹកមាត់ខាប់នៅដើមអណ្តាត ទឹកមាត់តែងហូរជ្រាបមកជានិច្ចឧបមាដូចអណ្តូងខ្សាច់ដែលបុគ្គលជីក មិនដែលរីងទឹកដូចម្តេចមិញ ទឹកមាត់យើងនេះ ក៏ជ្រាបសើមចេញមកពីក្នុងមាត់ពុំដែលដាច់ ដូចអណ្តូងខ្សាច់នោះឯង ។

១០). **សិង្ឃាណិកា** "ទឹកសម្បោរ" មានសម្បុរ-ស ដូចជាទឹកនៅក្នុងគ្រាប់ត្នោតខ្ចី បើបុគ្គលនោះមានជម្ងឺឈឺផ្តាសាយក្អក ទឹកសម្បោរក៏ហូរចេញមកតាមរន្ធច្រមុះ មានសភាពគួរខ្ពើមរអើមក្រៃពេកណាស់ ។

១១). **លសិកា** "ទឹករំអិល" នៅក្នុងសន្លាក់ឆ្អឹងទាំងពួង បើបុគ្គលនោះ មានទឹករំអិលក្នុងសន្លាក់ឆ្អឹងតិច នឹងដេក ដើរ ឈរ អង្គុយ មិនសូវរហ័សរហួន ហើយច្រើនលាន់ឮប្រស់១ បើសន្លាក់ឆ្អឹងនោះមានទឹករំអិលច្រើន មិនលាន់ឮឡើយ ហើយជាអ្នករហ័សវាងវៃផង ។

១២). **មុត្តំ** "ទឹកមូត្រ" មានសម្បុរដូចទឹកជ្រក់សណ្ដែករាជមាស កើតនៅក្នុងខាងក្រោម ស្ថិតនៅក្នុងក្រពះនោម ផ្លូវដែលទឹកមូត្រចូលទៅមិនប្រាកដ ប្រាកដតែទឹកហូរចេញ បើក្រពះនោះ មានទឹកមូត្រពេញហើយ សត្វទាំងឡាយ តែងខ្វល់ខ្វាតយថា "អញនឹងបន្ទោបង់នូវបស្សាវៈ" ដូច្នេះ ទឹកមូត្រដែលហូរចេញមកនោះ គួរខ្ពើមរអើមក្រៃពេក ។

## តេជោធាតុ

តេជោធាតុ "ធាតុភ្លើង" មាន៤យ៉ាងគឺ:

១). **សន្តប្បត្តិ** ភ្លើងធាតុធ្វើកាយ ឱ្យក្ដៅរោលរាល មិនឱ្យត្រជាក់ ។

២). **បរិទយ្ហត្តិ** ភ្លើងធាតុធ្វើកាយឱ្យអន្ទះអន្ទែង រសាប់រសល់ ។

៣). **ជរណត្តិ** ភ្លើងធាតុធ្វើកាយឱ្យទុរន់ទុរា ភ្នែកងងឹត ត្រចៀកថ្លង់ ធ្មេញបាក់ សក់ស្កូវ សាច់ក៏ជ្រួញជ្រីវ ជាដើម ។

៤). **បរិណាមត្តិ** ភ្លើងធាតុដុតអាហារឱ្យល្អិត ។

តេជោធាតុមានតែ៤ ប៉ុណ្ណោះ ។

*សូមឱ្យវិទូទាំងឡាយ មេត្តាជួយសម្រួល*
*នូវអត្ថបទធម៌នេះ ឱ្យមានសុពលភាព*
*ដើម្បីងាយស្រួល ដល់អ្នករៀន*
*សូមអរគុណ!!!*

♠ *By Bhikhu Tikhamuni@Chheng Oum, In Ottawa, Ontario, Canada*

## វាយោធាតុ

វាយោធាតុ "ធាតុខ្យល់" មាន៦យ៉ាងគឺ៖

១). **ឧទ្ធង្គមាវាត** ខ្យល់បក់ពីបាតជើងដរាបដល់សិរសា ។

២). **អធោគមាវាត** ខ្យល់បក់ពីសិរសាដរាបដល់បាតជើង ។

៣). **កុច្ឆិស្សយាវាត** ខ្យល់បក់វិលវល់នៅក្នុងពោះ ។

៤). **កោដ្ឋាសយាវាត** ខ្យល់បក់នៅក្នុងពោះវៀនតូច ពោះវៀនធំ ។

៥). **អង្គានុសារីវាត** ខ្យល់បក់សព្វសពាង្គកាយ ។

៦). **អស្សាសបស្សាស** ខ្យល់ដកដង្ហើមចេញចូល ត្រូវជាវាយោធាតុមាន៦ប្រការ ។

បថវីធាតុមាន២០, អបោធាតុមាន១២, តេជោធាតុមាន៤, វាយោធាតុមាន៦ រួមត្រូវជាមហាភូតរូប៤២ ព្រោះជាទីធំធេងជាងគេ នឹងជាទីលំនៅនៃរូបដទៃៗគ្រប់ៗមនុស្សទាំងអស់ ។

"ធម៌ទាំងឡាយមានចិត្តជាធំ មានចិត្តប្រសើរបំផុត សម្រេចមកពីចិត្ត បើបុគ្គលមានចិត្តត្រូវទោសប្រទូស្តហើយ ទោះបីនិយាយក្តី ធ្វើក្តី (ក៏អាក្រក់ដែរ) ព្រោះអំពើអាក្រក់នោះឯងហើយ រមែងនាំមកនូវសេចក្តីទុក្ខ ដេញជាប់តាមក្រោយបុគ្គលនោះ ដូចជាកង់រទេះវិល តាមស្នាមជើងគោ ដែលអូសនឹមរទេះ យ៉ាងដូច្នោះឯង" ។

Mind is the forerunner of (all evil) states. Mind is chief; mind-made are they. If one speaks or acts with wicked mind, because of that, suffering follows one, even as the wheel follows the hoof of the draught-ox.